ព្រឹត្តិបត្រព័ត៌មាន
# ការប្រែប្រួលអាកាសធាតុ
# ៤
នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
ខែមករា-មីនា
ឆ្នាំ២០១៦

## គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត

### ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ៖ ការប្រែក្លាយពីយុទ្ធសាស្ត្រទៅជាសកម្មភាពក្នុងឆ្នាំ២០១៥

សន្និបាតបូកសរុបការងារបរិស្ថានប្រចាំឆ្នាំរបស់ក្រសួងបរិស្ថាន ដែលបានប្រព្រឹត្តទៅកាលពីខែកុម្ភៈ ឆ្នាំ២០១៦ បានផ្តល់ឱកាសមួយសម្រាប់បង្ហាញពីវឌ្ឍនភាពនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដូចមានក្នុងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣។ លទ្ធផលវិជ្ជមានជាច្រើនបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីកិច្ចប្រឹងប្រែងរបស់នាយកដ្ឋានប្រែប្រួលអាកាសធាតុ (ន.ប.អ.) ក្នុងឆ្នាំ២០១៥ ដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័ននិងអ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិនិងក្រោមជាតិ។

- *ការរៀបចំស្ថាប័នប្រកបដោយប្រសិទ្ធិភាពសម្រាប់ការប្រែប្រួលអាកាសធាតុ៖* ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនិងអគ្គលេខាធិការដ្ឋានរបស់ខ្លួន ត្រូវបានបង្កើតនៅខែឧសភា ឆ្នាំ២០១៥ ដែលមាន ន.ប.អ.ជាសេនាធិការ។ ដោយមានតួនាទីសំខាន់លើការអភិវឌ្ឍដោយចីរភាព គ្របដណ្តប់ទាំងការប្រែប្រួលអាកាសធាតុផងនោះ ក្រុមប្រឹក្សាជាតិនេះ បានបង្កើនសមាជិកភាពរបស់ខ្លួន ដែលរួមបញ្ចូលទាំងមន្ត្រីជាន់ខ្ពស់តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី/ខេត្តទាំងអស់។

*បន្តទៅទំព័រទី២*

## កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

### កិច្ចព្រមព្រៀងអាកាសធាតុថ្មីត្រូវបានឯកភាពនៅ CoP 21 ទីក្រុងប៉ារីស



*ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងប្រតិភូកម្ពុជា ចូលរួមក្នុងកិច្ចប្រជុំមេដឹកនាំនៃសន្និសីទលើកទី២១ នៅទីក្រុងប៉ារីស ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥*

សន្និសីទបណ្តាភាគីលើកទី២១ (CoP 21) នៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ដែលបានប្រព្រឹត្តនៅទីក្រុងប៉ារីស ប្រទេសបារាំង កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយនៃការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។ ជាកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតដែលព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំប្រតិភូចំនួន ៤០រូប និងថ្លែងព្រះរាជសុន្ទរកថានៅក្នុងកិច្ចប្រជុំមេដឹកនាំនៃសន្និសីទនេះ។ ស្តែងពីទស្សនវិស័យរបស់កម្ពុជា កិច្ចព្រមព្រៀងអាកាសធាតុទីក្រុងប៉ារីសនេះ គឺជាជំហានថ្មីដ៏សំខាន់ ដែលយើងបានត្រៀមខ្លួនជាស្រេចក្នុងការផ្តួចផ្តើមដំណើរការផ្តល់សច្ចាប័ននៅឆ្នាំនេះ។

កម្ពុជា បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចចរចានេះ និងបានសហការជាមួយប្រទេសអភិវឌ្ឍន៍តិចតួច ចំនួនបី រួមមាន ប្រទេសហ្គាំប៊ី ម៉ាឡាវី និងសេនេហ្គាល់ ក្នុងការរៀបចំវេទិកាផ្លូវការ ដើម្បីចែករំលែកទម្លាប់ល្អនៃការអនុវត្តបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការពង្រឹងសមត្ថភាព

*បន្តទៅទំព័រទី៣*

**មាតិកាព័ត៌មាន**

**គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត**
- ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ៖ ការផ្លាស់ប្តូរពីយុទ្ធសាស្ត្រទៅជាការអនុវត្តក្នុងឆ្នាំ ២០១៥ ........ ១
- ជំនួយឥតសំណងការស្រាវជ្រាវនិងច្នៃប្រឌិតអំពីការប្រែប្រួលអាកាសធាតុ ........ ២
- ការកែសម្រួលប្រព័ន្ធទិន្នន័យមូលដ្ឋានជំនួយអភិវឌ្ឍន៍ផ្លូវការជួយឱ្យកម្ពុជាអាចតាមដានហិរញ្ញប្បទានអាកាសធាតុអន្តរជាតិ ល្អប្រសើរជាងមុន ........ ៣

**កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ**
- កិច្ចព្រមព្រៀងអាកាសធាតុថ្មីត្រូវបានឯកភាពនៅ CoP 21 ទីក្រុងប៉ារីស ........ ១

**ឯកសារបោះពុម្ពផ្សាយថ្មីៗ** ........ ៤

**សម្លេងពីមូលដ្ឋាន** ........ ៤

**ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ** ........ ៤

**ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ** ........ ៤

**ចំណាប់អារម្មណ៍របស់និពន្ធនាយក**

*សូមគោរពប្រិយមិត្តអ្នកអាន យើងខ្ញុំសូមស្វាគមន៍ចំពោះការអានព្រឹត្តិបត្រព័ត៌មានការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៦។ ព្រឹត្តិបត្រព័ត៌មាននេះនឹងចេញផ្សាយរៀងរាល់ត្រីមាស ដើម្បីឆ្លុះបញ្ចាំងពីការអភិវឌ្ឍគោលនយោបាយអាកាសធាតុថ្មីៗនៅកម្ពុជា ព្រមទាំងបច្ចុប្បន្នភាពការងារជាច្រើនដែលអនុវត្តក្រោមអណត្តិនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ដោយឡែកក្នុងត្រីមាសទី២និងទី៤ គឺពីរលេខក្នុងមួយឆ្នាំ យើងនឹងបន្ថែមការចែករំលែកបទពិសោធន៍ការងារសំខាន់ៗដែលអនុវត្តដោយអង្គការដៃគូ និងសហគមន៍នានាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ យើងខ្ញុំសង្ឃឹមថាប្រិយមិត្តអ្នកអាន នឹងចូលរួមជាមួយពួកយើងជាលក្ខណៈអចិន្ត្រៃយ៍ ឬមិនអចិន្ត្រៃយ៍ ក្នុងការពាំនាំសម្លេងពីមូលដ្ឋាន ដែលជាធាតុចូលចាំបាច់នាំឱ្យព្រឹត្តិបត្រនេះជោគជ័យ ក្នុងនាមជាប្រតិបត្តិករការងារប្រែប្រួលអាកាសធាតុ។*

**ក្រុមការងាររៀបចំនិងត្រួតពិនិត្យ**

ព្រឹត្តិបត្រព័ត៌មាននេះ ត្រូវបានរៀបចំ កែសម្រួល និងផលិតដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានជំនួយបច្ចេកទេសពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។

# គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

## ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ៖ ការប្រែក្លាយពីយុទ្ធ...

*បន្តពីទំព័រទី១*

- *ការរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់វិស័យមួយចំនួនបានល្អប្រសើរ៖* ក្នុងឆ្នាំ២០១៥ ក្រសួងស្ថាប័នដែលបានអនុម័តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ បានកើនឡើងពី៨ ទៅ ១៤។ ផែនការសកម្មភាពទាំងនេះ បានកំពុងបង្ហាញផ្លូវដល់វិស័យនានាក្នុងការអនុវត្តវិធានការបន្សាំនិងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ទៅតាមចំណុចអាទិភាព ហើយក៏ជាឧបករណ៍ក្នុងការកៀរគរមូលនិធិសម្រាប់បង្កើនការអនុវត្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុផងដែរ។
- *ការកសាងសមត្ថភាពនិងលើកកម្ពស់ការយល់ដឹងសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅថ្នាក់ក្រោមជាតិ៖* អាជ្ញាធរមូលដ្ឋាននិងសហគមន៍កាន់តែសកម្មចូលរួមឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សំដៅបង្កើនភាពធន់របស់ពួកគាត់។ ក្នុងឆ្នាំ២០១៥ ន.ប.អ.បានសហការជាមួយមន្ទីរបរិស្ថានខេត្តកំពង់ចាម កំពត និងពោធិ៍សាត់ ដោយមានការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា ក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការវិនិយោគឃុំ សង្កាត់ចំនួន៩។
- *ការរៀបចំឱ្យល្អប្រសើរដើម្បីកៀរគរហិរញ្ញប្បទានអាកាសធាតុតាមតម្រូវការចាំបាច់៖* ក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុដែលបានអនុម័តក្នុងឆ្នាំ២០១៥ បានកំណត់នូវប្រភពហិរញ្ញប្បទានអាកាសធាតុដែលមាននាពេលបច្ចុប្បន្ន និងនិន្នាការក្នុងរយៈពេល៥-១០ឆ្នាំខាងមុខ ក៏ដូចជាធ្វើការប៉ាន់ប្រមាណដំបូងនូវផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើសេដ្ឋកិច្ច និងរបៀបនៃការវិនិយោគឆ្លាតខាងអាកាសធាតុដែលអាចជួយកាត់បន្ថយផលប៉ះពាល់ទាំងនេះបាន។



*កសិកររៀនអំពីប្រភេទជំងឺដំណាំស្រូវ នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ*

- *ការកសាងប្រព័ន្ធដែលអាចសម្របសម្រួលនិងឆ្លើយតបកាន់តែមានប្រសិទ្ធិភាព៖* ដោយក្របខណ្ឌជាតិសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃការប្រែប្រួលអាកាសត្រូវបានបញ្ចប់នៅក្នុងឆ្នាំ២០១៥ និងដោយមានទិន្នន័យគោលដែលមានសូចនាករស្តង់ចំនួន៧ ក្នុងចំណោមសូចនាករចំនួន៨ ប្រទេសកម្ពុជាបានត្រៀមខ្លួនជាស្រេចក្នុងការអនុវត្តក្របខណ្ឌត្រួតពិនិត្យនិងវាយតម្លៃរបស់ខ្លួន។ ក្របខណ្ឌនេះ នឹងផ្តល់ព័ត៌មានសំខាន់ៗគាំទ្រដល់សេចក្តីសម្រេចចិត្តផ្អែកគោលនយោបាយនិងវិនិយោគ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

## ជំនួយឥតសំណងការស្រាវជ្រាវនិងច្នៃប្រឌិតអំពីការប្រែប្រួលអាកាសធាតុ

កាលពីខែកញ្ញា ឆ្នាំ២០១៥កន្លងទៅ នាយកដ្ឋានប្រែប្រួលអាកាសធាតុ (ន.ប.អ.) ដោយមានការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា បាន**ប្រកាសចាប់ផ្តើមផ្តល់ជំនួយឥតសំណងដល់គម្រោងស្រាវជ្រាវនិងច្នៃប្រឌិត** ដើម្បីជំរុញអ្នកសិក្សា អ្នកស្រាវជ្រាវ និងអ្នកច្នៃប្រឌិត ដែលកំពុងធ្វើការក្នុងស្ថាប័នរដ្ឋនិងអង្គការមិនមែនរដ្ឋាភិបាល នាំយកនូវគំនិតឆ្លាតវៃរបស់ពួកគេ គាំទ្រការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

តាមរយៈយន្តការនេះ ជំនួយឥតសំណងបានគាំទ្រទៅលើការសិក្សាស្រាវជ្រាវនិងច្នៃប្រឌិត។ សំណើគម្រោងស្រាវជ្រាវដែលបញ្ជូនមក ចាំបាច់ត្រូវបង្ហាញច្បាស់នូវគុណតម្លៃបន្ថែមសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ទិដ្ឋភាពសំខាន់ៗចំនួនបី ដែលមានចំណុចផ្តោតសំខាន់ចំនួន១១ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គឺ ១)បន្សាំ ២)ការកាត់បន្ថយនិងការរៀបចំសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និង ៣)បន្សាំ/ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។

ឯកសារទស្សនទានចំនួន៥០ដែលបានដាក់ស្នើសុំមូលនិធិ បានបង្ហាញពីចំណាប់អារម្មណ៍ខ្ពស់ចំពោះការប្រកាសផ្តល់ជំនួយឥតសំណងនេះ (ចន្លោះពី ៥០.០០០ដុល្លារ ទៅ ១០០.០០០ដុល្លារ ក្នុងមួយគម្រោង)។ តាមរយៈដំណើរការប្រកួតប្រជែង គម្រោងចំនួនប្រាំបីត្រូវបានជ្រើសរើស ហើយបច្ចុប្បន្ននេះកំពុងរៀបចំសំណើគម្រោងពេញលេញរបស់ខ្លួន។ គម្រោងទាំងនេះ មានដូចខាងក្រោម៖

១. ថាមពលកកើតឡើងវិញតាមរយៈការប្រើប្រាស់ថាមពលជីវម៉ាសសម្រាប់រោងចក្រកាត់ដេរនិងឧស្សាហកម្មផ្សេងៗ *(ស្នើដោយ៖ អង្គការក្រុមថាមពលកកើតឡើងវិញ បរិស្ថាន និងសាមគ្គីភាព ហៅកាត់ GERES)*

២. ការធ្វើតេស្តសាកល្បងបច្ចេកវិទ្យាឡជីវឧស្ម័នខ្នាតមធ្យម ១០-២០គីឡូវ៉ាត់ *(ស្នើដោយ៖ កម្មវិធីឡជីវឧស្ម័នជាតិ ហៅកាត់ NBP)*

៣. អតិក្រមសមាហរណកម្មបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់កសិករ តាមរយៈថាមពលកកើតឡើងវិញ ការគ្រប់គ្រងទឹកនិងដំណាំ



*ក្រុមការងារនៃកម្មវិធីជាតិត្រួតពិនិត្យជំងឺគ្រុនឈាមនៃក្រសួងសុខាភិបាល បង្កើតការតាមដានបាណកសាស្ត្រ នៅខេត្តបន្ទាយមានជ័យ*

សហគ្រាសខ្នាតតូចនិងមធ្យម *(ស្នើដោយ៖ ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា ហៅកាត់CRDT)*

៤. យុទ្ធសាស្ត្រនិងការសិក្សាស្រាវជ្រាវការគ្រប់គ្រងសំណល់រឹងសម្រាប់រាជធានីភ្នំពេញ *(ស្នើដោយ៖ អង្គការNexus )*

៥. ការសិក្សាស្រាវជ្រាវអំពីសន្ទស្សន៍ភាពងាយរងគ្រោះក្នុងវិស័យសុខាភិបាល *(ស្នើដោយ៖ ក្រសួងសុខាភិបាល)*

៦. ការសិក្សាស្រាវជ្រាវអំពីអត្ថប្រយោជន៍នៃទម្លាប់ធ្វើកសិកម្មបែបអភិរក្ស *(ស្នើដោយ៖ អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)*

៧. យុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់តំបន់វ៉ាមសារ *(ស្នើដោយ៖ មន្ទីរបរិស្ថានខេត្តស្ទឹងត្រែង)*

៨. បច្ចេកវិទ្យាព័ត៌មានពីចម្ងាយសម្រាប់ពិនិត្យតាមដានតំបន់ការពារ/ព្រៃរបោះ *(ស្នើដោយ៖ អង្គការសង្គមដើម្បីអភិរក្សសត្វព្រៃ ឬWCS)*។

*ព្រឹត្តិបត្រព័ត៌មាននេះ នឹងធ្វើបច្ចុប្បន្នភាពអំពីដំណើរការនិងព័ត៌មានលម្អិតនៃគម្រោងទាំងនេះនៅក្នុងលេខបន្ទាប់។*

## ការកែសម្រួលប្រព័ន្ធទិន្នន័យមូលដ្ឋានជំនួយអភិវឌ្ឍន៍ផ្លូវការជួយឱ្យកម្ពុជាអាចតាមដានហិរញ្ញប្បទានអាកាសធាតុអន្តរជាតិ ល្អប្រសើរជាងមុន

ដោយមានការប្តេជ្ញាចិត្តលើហិរញ្ញប្បទានអាកាសធាតុសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុកាលពីខែធ្នូ ឆ្នាំ២០១៥ ហិរញ្ញប្បទានអាកាសធាតុអន្តរជាតិនឹងមានការកើនឡើងនៅឆ្នាំបន្តបន្ទាប់ ហើយក៏នឹងក្លាយជាប្រភពហិរញ្ញប្បទានសកម្មភាពអាកាសធាតុសំខាន់សម្រាប់កម្ពុជា។

នាយកដ្ឋានប្រែប្រួលអាកាសធាតុ បានចុះកិច្ចព្រមព្រៀងរួមគ្នាជាមួយគណៈកម្មការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅខែកញ្ញា ឆ្នាំ២០១៥ ដើម្បីកែសម្រួលប្រព័ន្ធទិន្នន័យមូលដ្ឋានជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA system) ដែលអាចឱ្យកម្ពុជាតាមដានលំហូរហិរញ្ញប្បទានអាកាសធាតុអន្តរជាតិ បានល្អប្រសើរជាងមុន។ ចំនុចផ្តោតនៃកិច្ចប្រឹងប្រែងក្នុងការតាមដានលំហូរហិរញ្ញប្បទានទាំងបន្សាំ និងការកាត់បន្ថយ រួមមាន៖



ផលប៉ះពាល់រយៈពេលវែងនៃការប្រែប្រួលអាកាសធាតុនិងហិរញ្ញប្បទានអាកាសធាតុទៅលើផលិតផលក្នុងស្រុកសរុប (GDP)


មន្ត្រីគណៈកម្មការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា និងមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កត់ត្រាទិន្នន័យគោល ODA ឆ្នាំ២០១៣-២០១៤ នៅខេត្តព្រះសីហនុ ខែធ្នូ ឆ្នាំ២០១៥

- ការកែសម្រួលប្រព័ន្ធកត់ត្រាទិន្នន័យហិរញ្ញប្បទានប្រែប្រួលអាកាសធាតុតាមទម្រង់ថ្មី ជួយឱ្យម្ចាស់ជំនួយអាចកត់ត្រាគម្រោងជាច្រើនទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។
- ការកែសម្រួលការកត់ត្រាតាមវិស័យនិងអនុវិស័យ ដោយរួមបញ្ចូលទាំងលទ្ធភាពក្នុងតាមដានហិរញ្ញប្បទានប្រែប្រួលអាកាសធាតុថ្មីនិងបន្ថែម។

មន្ត្រីបច្ចេកទេសនៃគណៈកម្មការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជាសរុបជាង២០នាក់ បានទទួលការបណ្តុះបណ្តាលអំពីវិធីសាស្ត្រនៃការកត់ត្រាទិន្នន័យហិរញ្ញប្បទានអាកាសធាតុ។ មន្ត្រីទាំងនោះបានឱ្យដឹងថាទម្រង់ថ្មីនេះផ្តល់ភាពងាយស្រួលជាងមុន និងជួយកត់ត្រាប្រភពហិរញ្ញវត្ថុខាងក្រៅទាក់ទងនឹងការប្រែប្រួលអាកាសធាតុបានល្អប្រសើរជាងមុន។

# កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

## កិច្ចព្រមព្រៀងអាកាសធាតុថ្មីត្រូវបានឯកភាពនៅ CoP 21 ...

*បន្តពីទំព័រទី១*

កៀរគរហិរញ្ញប្បទានសម្រាប់សកម្មភាពបន្សាំ។

លទ្ធផលសំខាន់ៗនៃកិច្ចព្រមព្រៀងក្នុង CoP 21 គឺជាភាពជោគជ័យជាប្រវត្តិសាស្ត្រសម្រាប់ប្រជាជាតិជុំវិញពិភពលោក មានដូចខាងក្រោម៖

- ខិតខំបន្តកាត់បន្ថយសីតុណ្ហភាពមិនឱ្យកើនឡើងលើស១,៥អង្សាសេលស៊ុស ដែលអាចធានានូវកំណើនសីតុណ្ហភាពពិភពលោក "ស្ថិតនៅក្រោម" ២អង្សាសេលស៊ុស (ធៀបនឹងកម្រិតមុនបដិវត្តន៍ឧស្សាហកម្ម)។
- កាត់បន្ថយកម្រិតបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឱ្យបានកាន់តែឆាប់តាមដែលអាចធ្វើបាន និងសម្រេចបាននូវតុល្យភាពរវាងប្រភពនិងអាងស្រូបឧស្ម័នផ្ទះកញ្ចក់នៅពាក់កណ្តាលចុងសតវត្សរ៍នេះ។
- ពិនិត្យមើលវឌ្ឍនភាពតាមរយៈការធ្វើបច្ចុប្បន្នភាពរបាយការណ៍ស្តីពីការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (INDC) រៀងរាល់៥ឆ្នាំម្តង ក្នុងការត្រួតពិនិត្យកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- បណ្តាប្រទេសអភិវឌ្ឍន៍នឹងបន្តខិតខំប្រឹងប្រែងគ្រប់មធ្យោបាយ ក្នុងការកៀរគរមូលនិធិឱ្យបាន១០០ពាន់លានដុល្លាក្នុងមួយឆ្នាំត្រឹមឆ្នាំ២០២៥ ដើម្បីគាំទ្រសកម្មភាពអាកាសធាតុក្នុងប្រទេសកំពុងអភិវឌ្ឍន៍។
- ផ្តល់នូវហិរញ្ញប្បទានកាន់តែច្រើនសម្រាប់បន្សាំ និងការផ្ទេរបច្ចេកវិទ្យាដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយគាំទ្រជាពិសេសដល់ប្រទេសអភិវឌ្ឍន៍តិចតួច និងសម្ព័ន្ធប្រទេសកោះតូចៗ។



ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងជាប្រតិភូកម្ពុជា ចែករំលែកការអនុវត្តល្អៗនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ក្នុងសន្និសីទលើកទី២១ នាខែធ្នូ ឆ្នាំ២០១៥

- ជំរុញការកសាងសមត្ថភាព ជាពិសេសសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច ប្រទេសនៅទ្វីបអាហ្វ្រិក ប្រទេសកោះតូចៗនៅមហាសមុទ្របាស៊ីហ្វិក និងអាត្លង់ទិក ក្នុងការអនុវត្តផែនការសកម្មភាពសម្រាប់កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងបន្សាំ។
- កសាងសមត្ថភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីពង្រឹងប្រព័ន្ធតាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់។

ក្នុងនាមជាភាគីនៃអនុសញ្ញាUNFCCC កម្ពុជាបានដាក់ជូននូវរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (http://camclimate.org.kh/en/documents-and-media/library/category/137-national-report.html) កាលពីខែកញ្ញា ឆ្នាំ២០១៥ ទៅកាន់លេខាធិការដ្ឋានអនុសញ្ញានេះ មុនការប្រារព្ធសន្និសីទបណ្តាភាគីលើកទី២១។

## ឯកសារបោះពុម្ពផ្សាយថ្មីៗ

១) ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ក្រសួងបរិស្ថាន (ខ្មែរនិងអង់គ្លេស), http://www.camclimate.org.kh/en/documents-and-media/library/category/128-climate-change-action-plan.html

២) របាយការណ៍ជាតិលើកទី២ស្តីពីការប្រែប្រួលអាកាសធាតុ បញ្ជូនទៅកាន់លេខាធិការដ្ឋានUNFCCC (អង់គ្លេស), http://www.camclimate.org.kh/en/documents-and-media/library/category/137-national-report.html

៣) របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញាUNFCCC (អង់គ្លេស), http://www.camclimate.org.kh/en/documents-and-media/library/category/137-national-report.html

## ការចេញផ្សាយបន្ទាប់



### សម្លេងពីមូលដ្ឋាន

កសិករជាច្រើននិយាយថា ពួកគាត់កាន់តែពិបាកក្នុងការដាំដុះពូជស្រូវធ្ងន់ដោយសារតែទឹកភ្លៀងមិនគ្រប់គ្រាន់។ ពួកគាត់និយាយថា "មិនមានជម្រើសអ្វីផ្សេងក្រៅពីរង់ចាំភ្លៀងធ្លាក់ឡើយ"។ កសិករម្នាក់មកពីខេត្តព្រៃវែង នឹងចែករំលែកបទពិសោធន៍ "ការផ្លាស់ប្តូរពូជស្រូវថ្មី និងបច្ចេកទេសដាំដុះ" នៅក្នុងលេខចេញផ្សាយបន្ទាប់។

✎ សូមចុះឈ្មោះជាអ្នកចូលរួមចំណែកបង្ហាញសម្លេងពីមូលដ្ឋានជាអចិន្ត្រៃយ៍ ឬមិនអចិន្ត្រៃយ៍ ដោយការផ្ញើអត្ថបទ មកសារអេឡិចត្រូនិក: reaksmey.neou@camclimate.org.kh

## ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ



### ទស្សនៈប្រជាជនចំពោះការប្រែប្រួលអាកាសធាតុ

ការសិក្សាលើកទីពីរស្តីពី*ការស្វែងយល់ទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា៖* ចំណេះដឹង ឥរិយាបទ និងការអនុវត្ត (KAP2) បានបង្ហាញពីទស្សនៈប្រជាជនទូទាំងប្រទេសចំពោះការប្រែប្រួលអាកាសធាតុនិងបញ្ហាប្រឈមរបស់ខ្លួន។ លទ្ធផលសំខាន់ៗក្នុងKAP2 ត្រូវបានបង្ហាញ៖

- ៩០%នៃអ្នកឆ្លើយតប មានការយល់ដឹងចំពោះការប្រែប្រួលអាកាសធាតុពីកម្រិតមធ្យម ទៅខ្ពស់។
- ប្រជាជនភាគច្រើនបានកំពុងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ចំណែកឧបសគ្គចម្បងរបស់ពួកគេគឺ កង្វះខាតថវិកា និងសមត្ថភាពធនធានមនុស្ស។
- មានឱកាសជាច្រើនសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ រួមបញ្ចូលទាំងការបង្កើនលទ្ធភាពក្នុងការទទួលបានព័ត៌មាន និងការប្តេជ្ញាចិត្តខ្ពស់របស់រដ្ឋាភិបាល។



### សទ្ទានុក្រមការប្រែប្រួលអាកាសធាតុ

សទ្ទានុក្រមការប្រែប្រួលអាកាសធាតុ ត្រូវបានចងក្រង ដើម្បីធានានូវសង្គតិភាពនិងភាពត្រឹមត្រូវនៃការប្រើប្រាស់ពាក្យបច្ចេកទេសការប្រែប្រួលអាកាសធាតុ។ ពាក្យបច្ចេកទេសនៅក្នុងសទ្ទានុក្រមនេះ ទាក់ទងនឹងវិទ្យាសាស្ត្រការប្រែប្រួលអាកាសធាតុ មូលហេតុនិងផលប៉ះពាល់ បន្សាំ ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ គ្រោះមហន្តរាយ សេចក្តីសម្រេចចិត្តថ្នាក់ជាតិនិងអន្តរជាតិ អេកូឡូស៊ី និងបរិស្ថាន។ សទ្ទានុក្រមនេះ មានពាក្យបច្ចេកទេសសរុបប្រមាណ៥០០ពាក្យ និងបញ្ជីអក្សរបំព្រួញប្រើប្រាស់ជាអន្តរជាតិ។ បច្ចុប្បន្ននេះ សទ្ទានុក្រមការប្រែប្រួលអាកាសធាតុកំពុងទទួលការត្រួតពិនិត្យដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ។

## ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ

ខែមេសា៖ សិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការប្រែប្រួលអាកាសធាតុ សម្រាប់អ្នកដឹកនាំវ័យក្មេងក្រសួងបរិស្ថាន
ខែមេសា៖ វគ្គបណ្តុះបណ្តាលសម្រាប់ដៃគូអភិវឌ្ឍន៍អំពីការតាមដានហិរញ្ញប្បទានអាកាសធាតុ
ខែមេសា៖ ការផ្សព្វផ្សាយក្របខណ្ឌជាតិសម្រាប់ពិនិត្យតាមដាននិងវាយតម្លៃការប្រែប្រួលអាកាសធាតុ
ខែមេសា៖ ការផ្តល់ជំនួយឥតសំណងពីកម្មវិធី CCCA ទៅដល់ក្រសួងស្ថាប័នដែលបានអនុម័ត CCAPs (ជុំទី២)
ខែមេសា៖ សិក្ខាសាលាការជ្រើសរើសឧបករណ៍វាយតម្លៃហានិភ័យអាកាសធាតុ
ខែមេសា៖ កិច្ចប្រជុំតុមូលស្តីពីការកំណត់គម្រោងដើម្បីសិក្សាលម្អិតពីលទ្ធភាពសម្រាប់រៀបចំសំណើគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ
ខែមេសា៖ ការចុះប្រមូលទិន្នន័យអំពីវិធានការបន្សាំក្នុងខេត្តកោះកុង និងមណ្ឌលគិរី ដើម្បីចងក្រងជាឯកសារ
ខែឧសភា៖ សិក្ខាសាលាចែករំលែកចំណេះដឹង ស្តីពីការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ
ខែឧសភា៖ សិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅកាន់មន្ទីរបរិស្ថានខេត្ត និងក្រុមប្រឹក្សាឃុំ សង្កាត់
ខែឧសភា៖ កិច្ចប្រជុំពិគ្រោះយោបល់ដើម្បីរៀបចំវិធីសាស្ត្រសិក្សាលទ្ធភាពគម្រោងលម្អិតពេញលេញ
ខែឧសភា-មិថុនា: វគ្គបណ្តុះបណ្តាលជាន់ខ្ពស់ស្តីពីការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការបន្សាំសម្រាប់ក្រុមការងារបន្សាំកម្មវិធី SPCR
ខែឧសភា-មិថុនា៖ សិក្ខាសាលាអភិវឌ្ឍន៍កម្មវិធីសិក្សាកម្រិតសាកលវិទ្យាល័យ
ខែមិថុនា៖ កិច្ចប្រជុំលើកទី១នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
ខែមិថុនា៖ ការពិនិត្យ និងការបង្កើតគោលការណ៍ណែនាំ/ឧបករណ៍សម្រាប់សិក្សាការប្រែប្រួលអាកាសធាតុសម្រាប់ក្រសួងសំខាន់ៗ ព្រមទាំងសិក្ខាសាលាពិគ្រោះយោបល់
ខែមិថុនា៖ កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីប្រសិទ្ធិភាពសូចនាករគម្រោងបន្សាំរបស់កម្មវិធី SPCR។

*សម្រាប់ព័ត៌មានទាក់ទងនឹងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឬឯកសារបោះពុម្ពថ្មីៗ សូមតាមដានគេហទំព័រ www.camclimate.org.kh*

### គាំទ្រដោយ

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP, SWEDEN

### អាសយដ្ឋានទាក់ទង

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
ស្ថិតក្នុងក្រសួងបរិស្ថាន អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (+៨៥៥-២៣) ៦៣១ ៨៣៧០ | សារអេឡិចត្រូនិក៖ admin@camclimate.org.kh
គេហទំព័រ៖ www.camclimate.org.kh